**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ: ១៩២៧ មស.ក្រខ

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន**
**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ស្តីពីការជ្រើសរើសមន្ត្រីរាជការស៊ីវិល និងការអនុវត្តកម្មសិក្សា សម្រាប់ផែនការក្របខណ្ឌឆ្នាំ២០២០។

**យោង ៖**
- លិខិតលេខ៥៧៤៥ មស.ក្រខ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ៣៣៧៥ សហវ.អថ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ប្រធានស្ថាប័ននិងអង្គភាព និងឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត មេត្តាជ្រាបថា: អនុលោមតាមស្មារតីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការផ្អាកជាបណ្តោះអាសន្ននូវការជ្រើសរើសក្របខណ្ឌថ្មីឱ្យចូលបម្រើការងារជាមន្ត្រីរាជការសម្រាប់ឆ្នាំ២០២០ ក្រសួង ស្ថាប័ន អង្គភាពទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមវិធានការមួយចំនួនដូចខាងក្រោម រហូតដល់មានការជូនដំណឹងជាថ្មីរបស់រាជរដ្ឋាភិបាល៖

១-ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមិនទាន់បានរៀបចំការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិលឆ្នាំ២០២០ ត្រូវផ្អាកដំណើរការជាបណ្តោះអាសន្នសិន

២-ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំពុងទទួលពាក្យសុំសិទ្ធិប្រឡងហើយ ឬបានបញ្ចប់ការទទួលពាក្យសុំសិទ្ធិប្រឡង សូមរក្សាសំណុំឯកសាររបស់បេក្ខជន សម្រាប់ការប្រឡងនៅពេលមានការអនុញ្ញាតជាថ្មី

៣-ក្រសួង ស្ថាប័ន ដែលបានដំណើរការប្រឡងរួចហើយ ប៉ុន្តែមិនទាន់បញ្ចប់នីតិវិធីជាស្ថាពរ ត្រូវរក្សាឯកសារ និង លទ្ធផលដែលទទួលបានក្នុងពេលកន្លងមក ដើម្បីបន្តនីតិវិធីនៃការប្រឡងបញ្ចប់នៅពេលមានការអនុញ្ញាតពេលក្រោយ

៤-ក្រសួង ស្ថាប័ន ដែលបានប្រឡងបញ្ចប់ស្ថាពរ និង/ឬ ទទួលបានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ ត្រូវរក្សាលទ្ធផលនេះ ហើយការអនុវត្តកម្មសិក្សាជាផ្លូវការមិនទាន់ត្រូវបានអនុញ្ញាតទេ រហូតដល់មានការអនុញ្ញាតជាថ្មីពីរាជរដ្ឋាភិបាល

៥-ចំពោះសិស្សមន្ត្រីជាន់ខ្ពស់ និងសិស្សមន្ត្រីក្រមការ សាលាភូមិន្ទរដ្ឋបាលដែលបានបែងចែកទៅបំពេញការងារតាមក្រសួង ស្ថាប័ន សរុបចំនួន ១៦៤នាក់ (មន្ត្រីជាន់ខ្ពស់ ៦០នាក់ មន្ត្រីក្រមការ ១០៤នាក់) ត្រូវបន្តការធ្វើកម្មសិក្សា និងទទួលបៀវត្សជាធម្មតា។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើសូម សម្តេច ឯកឧត្តម លោកជំទាវ មេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ៕

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ព្រុំ សុខា**

**ចម្លងជូន៖**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ